នស/រកត/០២១២/០៧៩

# ព្រះរាជក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលសរសេរជាអក្សរកាត់ថា គ.អ.ឆ.ក. ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ។

### ជំពូកទី២
### រចនាសម្ព័ន្ធ

**មាត្រា ២.-**

**គ.អ.ឆ.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ | | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | ០១ រូប | សមាជិក |
| - តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ០១ រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | ០១ រូប | សមាជិក |

- តំណាងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួង
រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
- អគ្គលេខាធិការ គ.អ.ឆ.ក. សមាជិក

សមាសភាពជាក់ស្តែងរបស់ គ.អ.ឆ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

គ.អ.ឆ.ក. មានភារកិច្ចអនុវត្តការងាររបស់ខ្លួនលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា លើទិដ្ឋភាពនគរូបនីយកម្ម បរិស្ថាន និងទេសចរណ៍។

**មាត្រា ៤.-**

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានមួយជាសេនាធិការជូន គ.អ.ឆ.ក. សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមានទីស្នាក់ការនៅក្រសួងទេសចរណ៍។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់គ.អ.ឆ.ក.

**មាត្រា ៥.-**

គ.អ.ឆ.ក. មានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្រ្ត ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- រៀបចំបទដ្ឋានគតិយុត្តនិងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រ ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តរភាពបរិស្ថាន
- ពិនិត្យ បង្ការ និងចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃរាល់គម្រោងអភិវឌ្ឍនិងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឲ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យនិងផ្តល់មតិជូនស្ថាប័នសមត្ថកិច្ច ចំពោះសំណើសុំវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- ពិនិត្យ តាមដាន និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព
- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួល ការងារខាងលើឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ គ.អ.ឆ.ភ.
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.អ.ឆ.ភ.

**មាត្រា ៦.-**

គ.អ.ឆ.ភ. ត្រូវប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន គ.អ.ឆ.ភ. អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

**មាត្រា ៧.-**

គ.អ.ឆ.ភ. មានសិទ្ធិស្នើសុំកម្លាំងអន្តរាគមន៍ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងករណីចាំបាច់។

**មាត្រា ៨.-**

គ.អ.ឆ.ភ. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**មាត្រា ៩.-**

អគ្គលេខាធិការដ្ឋាននៃ គ.អ.ឆ.ភ. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង មួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.អ.ឆ.ភ. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១០.-**

គ.អ.ឆ.ភ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា ១១.-**

បទបញ្ជាផ្ទៃក្នុង បែបបទ និងនីតិវិធីការងាររបស់ គ.អ.ឆ.ភ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.អ.ឆ.ភ.

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១២.-**

គ.អ.ឆ.ក. មានថវិកាដោយឡែករបស់ខ្លួនដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍។

គ.អ.ឆ.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូរអភិវឌ្ឍនិងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី 13 ខែ កុម្ភៈ ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៤.១២០២.០៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា